*ការិយាល័យជំនួយជនភៀសខ្លួន និងជនអន្តោប្រវេសន៍*
*រដ្ឋបាលសេវាសេដ្ឋកិច្ច*

Washington State
Department of Social & Health Services
Transforming lives

# *ព័ត៌មានសំខាន់ស្តីពីការផ្លាស់ប្តូរផ្សេងៗទៅលើវិធាន អន្តោប្រវេសន៍លើអត្ថប្រយោជន៍សាធារណៈ*

ក្រសួងសង្គមកិច្ច និងសុខាភិបាលរបស់រដ្ឋវ៉ាស៊ីនតោន យល់ដឹងថា ក្រសួងសន្តិសុខមាតុភូមិសហព័ន្ធបានបោះពុម្ពវិធានស្ថាពរដែលអាចអនុវត្តបានទៅលើមនុស្សដែលទទួលបានអត្ថប្រយោជន៍សាធារណៈផ្សេងៗដែលមានការបញ្ជាក់។ យើងបានពិនិត្យឡើងវិញនូវវិធានទាំងនេះ និងចង់ផ្តល់ព័ត៌មានត្រឹមត្រូវដែលអាចទុកចិត្តបានសម្រាប់បុគ្គលម្នាក់ៗ និងបណ្តាគ្រួសារនានាដែលអាចរងផលប៉ះពាល់ដោយគោលនយោបាយផ្លាស់ប្តូរបែបនេះ។ នេះគឺជាអ្វីដែលយើងដឹង ៖

- កម្មវិធី និងសេវាកម្មនានាដែលបានគ្រប់គ្រងដោយក្រសួងសង្គមកិច្ច និងសុខាភិបាលរដ្ឋវ៉ាស៊ីនតោន នឹងរក្សានៅដដែល ហើយអាចចូលប្រើបានសម្រាប់អ្នកដែលមានសិទ្ធិទទួលបាន។

- DSHS បន្តការពារការសម្ងាត់នៃព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជន និងមិនចែករំលែកព័ត៌មាននេះឡើយ លុះត្រាតែបានតម្រូវដោយច្បាប់រដ្ឋ ឬសហព័ន្ធ។

- ការផ្លាស់ប្តូរនានាអាចជះឥទ្ធិពលដល់ប្រជាជនជាក់លាក់ដែលកំពុងដាក់ពាក្យសុំការស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់ (ប័ណ្ណបៃតង) ឬការអនុញ្ញាតឱ្យចូលសហរដ្ឋអាមេរិក រួមទាំងជនអន្តោប្រវេសន៍ដែលកាន់ទិដ្ឋាការផ្សេងៗគ្នា និងការដាក់ពាក្យសុំបន្តជាថ្មី ផ្លាស់ប្តូរ ឬពន្យារទិដ្ឋាការក្នុងសហរដ្ឋអាមេរិក។

- វិធាននេះមិនប៉ះពាល់ដល់អ្នករស់នៅអចិន្ត្រៃស្របច្បាប់ដែលកំពុងដាក់ពាក្យសុំសញ្ជាតិ ឬចូលជាសញ្ជាតិអាមេរិកឡើយ។

- វិធានថ្មីនេះមិនអនុវត្តទៅលើជនអន្តោប្រវេសន៍គ្រប់រូបទាំងអស់ឡើយ។ វាមិនអនុវត្តទៅលើប្រជាជនដែលជាជនភៀសខ្លួន អ្នកកាន់ទិដ្ឋាការជនអន្តោប្រវេសន៍ពិសេសជនជាតិអាហ្វហ្គានីស្ថាន និងអ៊ីរ៉ាក់ អ្នកចូលជាជនជាតិគុយបារ/ហៃទី អ្នកដែលគេដោះលែងមនុស្សធម៌ ជនរងគ្រោះពីការជួញដូរមនុស្ស (ទិដ្ឋាការអក្សរ T) ជនរងគ្រោះពីសកម្មភាពឧក្រិដ្ឋកម្ម (ទិដ្ឋាការអក្សរ U) ជនអន្តោប្រវេសន៍អនីតិជនពិសេស ឬអ្នកដាក់ញត្តិទាមទារខ្លួនឯងអំពី VAWA (ច្បាប់អំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ)។

- ពីមុន មន្ត្រីនឹងរាប់តែការប្រើប្រាស់ជំនួយសាច់ប្រាក់ ឬសភាពដែលស្នាក់នៅព្យាបាលនៅមន្ទីរពេទ្យវេជ្ជសាស្ត្ររយៈពេលយូររបស់អ្នកជម្ងឺប៉ុណ្ណោះ នៅពេលពិចារណាលើការដាក់ពាក្យសុំទិដ្ឋាការរបស់ពួកគេ។ ការផ្លាស់ប្តូរនានានឹងបន្ថែមការថែទាំសុខភាព អាហារូបត្ថម្ភ និងអត្ថប្រយោជន៍លំនៅដ្ឋានសហព័ន្ធជាក់លាក់។

- វិធាននេះនឹងមិនអនុវត្តជាប្រតិសកម្មទៅលើអត្ថប្រយោជន៍ផ្សេងៗដែលត្រូវបានទទួលមុនពេលកាលបរិច្ឆេទប្រសិទ្ធភាពរបស់វិធាននេះឡើយ។ អត្ថប្រយោជន៍សហព័ន្ធបន្ថែមនឹងត្រូវបានពិចារណា តែប្រសិនបើបុគ្គលម្នាក់ដែលបានដាក់ពាក្យសុំ គឺមានការបញ្ជាក់សម្រាប់វា ឬទទួលបានអត្ថប្រយោជន៍នានា បន្ទាប់ពីវិធាននេះក្លាយជាមានប្រសិទ្ធភាពប៉ុណ្ណោះ។ ជាលទ្ធផលនៃការដាក់វិធានពីតុលាការដែលរាំងខ្ទប់វិធាននេះ យើងមិនដឹងពីកាលបរិច្ឆេទដែលវាអាចប្រែជាមានប្រសិទ្ធភាពឡើយ។

បានបោះពុម្ពផ្សាយនៅ ថ្ងៃទី 22 ខែតុលា ឆ្នាំ 2019

បន្តនៅទំព័របន្ទាប់

- ការផ្លាស់ប្តូរនានានឹងមិនអនុវត្តទៅលើគ្រប់ប្រភេទទាំងអស់នៃអត្ថប្រយោជន៍សហព័ន្ធឡើយ។ សម្រាប់បញ្ជីអត្ថប្រយោជន៍ដែលត្រូវបានបញ្ចូល ឬលើកលែង សូមមើលសំណួរចោទសួរជាញឹកញាប់។ គ្មានការផ្លាស់ប្តូរណាកំពុងត្រូវបានធ្វើឡើងទៅលើអត្ថប្រយោជន៍រដ្ឋឡើយ ទោះបីជាជំនួយសាច់ប្រាក់រដ្ឋ និងក្នុងមូលដ្ឋាននឹងបន្តត្រូវបានពិចារណា។

- វាមិនរាប់ការប្រើប្រាស់នូវអត្ថប្រយោជន៍នានាដោយសមាជិកគ្រួសាររបស់បុគ្គលម្នាក់ឡើយ។ ការប្រើប្រាស់នូវអត្ថប្រយោជន៍នានាដោយកុមារ ឬសមាជិកគ្រួសារដទៃទៀត នឹងមិនត្រូវបានរាប់ទល់នឹងបុគ្គលម្នាក់ដែលកំពុងដាក់ពាក្យសុំការស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់ (ប័ណ្ណបៃតង) ឬការអនុញ្ញាតឱ្យចូលសហរដ្ឋអាមេរិកឡើយ។

បុគ្គលម្នាក់ៗ និងបណ្តាគ្រួសារនានាដែលមានសំណួរ ឬក្តីកង្វល់ផ្សេងៗអំពីផលប៉ះពាល់នៃការប្រើប្រាស់អត្ថប្រយោជន៍សាធារណៈនានាលើស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ គួរតែទាក់ទងទៅមេធាវីអន្តោប្រវេសន៍។ ធនធានផ្សេងៗគឺអាចរកបានតាមរយៈមួយក្នុងចំណោមអង្គការដែលមានរាយនៅលើគេហទំព័ររបស់អភិបាល ៖ https://www.governor.wa.gov/issues/issues/safe-communities/immigration-and-refugee-resources។

បន្ថែមលើសនេះ អ្នកអាចទាក់ទងមួយក្នុងចំណោមអង្គការខាងក្រោមសម្រាប់ជំនួយ ៖

- ខ្សែបណ្តាញទាន់ហេតុការណ៍ CLEAR ៖ 1-888-201-1014
- គម្រោងសិទ្ធិជនអន្តោប្រវេសន៍ទិសពាយព្យ (NWIRP) ៖
  – ការិយាល័យ NWIRP Seattle ៖ 206-587-4009
  – ការិយាល័យ NWIRP Yakima Valley (Granger) ៖ 509-854-2100
  – ការិយាល័យ NWIRP Wenatchee ៖ 509-570-0054

Washington State
Department of Social & Health Services
*Transforming lives*

បានបោះពុម្ពផ្សាយនៅ ថ្ងៃទី 22 ខែតុលា ឆ្នាំ 2019